ក្រុមសៀវភៅការរុករកឃើញ®

# កម្លាំង
# នៅក្នុងភាពកម្សោយ

## អំណាចចេស្តាព្រះ ក្នុងកន្លែងដែលយើងមិននឹកស្មាន



និពន្ធដោយ : Dan Schaeffer



*សេចក្ដីផ្ដើម*

# កម្លាំង នៅក្នុងភាពកម្សោយ

## អំណាចបេស្ដាព្រះ
## ក្នុងកន្លែងដែលយើងមិននឹកស្មាន

**ក្នុងពិភពលោកនេះ** មានរឿងតិចណាស់ ដែលមានអំណាចកែប្រែជីវិតយើងឲ្យបានល្អប្រសើរឡើង។ ប៉ុន្តែ ការផ្សាយពាណិជ្ជកម្ម នៅហាងលក់សៀវភៅ ទូរទស្សន៍ និងវិទ្យុ បានផ្សព្វផ្សាយអំពីសៀវភៅជាច្រើន ដែលសន្យាថា នឹងកែប្រែជីវិតរបស់យើងឲ្យកាន់តែល្អឡើង។ សៀវភៅទាំងនោះមាន ដូចជា សៀវភៅ *គ្មានអ្វីផ្លាស់ប្ដូរទេ ទាល់តែអ្នកផ្លាស់ប្ដូរជាមុនសិន* សៀវភៅ *គិត ដើម្បីក្លាយជាអ្នកមាន* សៀវភៅ *អំណាចនៃពេលបច្ចុប្បន្ន* សៀវភៅ *ច្បាប់ទាំង៤៨ នៃអំណាច ។ល។* មនុស្សជាច្រើនមានការប្រឹងប្រែងយ៉ាងខ្លាំង នៅក្នុងការស្វែងរកភាពល្អប្រសើរជាងមុន។ តើមកពីហេតុអ្វី? ព្រោះយើងម្នាក់ៗ មានភាពកម្សោយជាច្រើន ដែលយើងមានចិត្តស្រេកឃ្លាន ចង់លប់បំបាត់ ហើយជំនួសមកវិញដោយភាពខ្លាំង។

នៅក្នុងទំព័រដែលមានជាបន្តបន្ទាប់នេះ លោកឌែន ស្ក្រេហ្វ័រ(Dan Schaeffer) សូមលើកឡើង អំពីផ្លូវឆ្ពោះទៅរកភាពខ្លាំង ដែលមនុស្សជាច្រើនមិននឹកស្មានដល់។

*នាំមកជូនដោយនំម៉ាណាប្រចាំថ្ងៃ*

contents

*ទី១*

**ការទទួលស្គាល់ការពិត ..........................................៦**

*ទីពីរ*

**ការផ្លាស់ប្តូរទស្សនៈរបស់យើង ............................. ១០**

*ទី៣*

**ការទាត់កំប៉ុងដែលបាក់បែក................................. ១៦**

*ទី៤*

**ការទទួលស្គាល់អំណាចចេស្តាព្រះ ...........................២៤**

MANAGING EDITOR: J. R. Hudberg
COVER DESIGN: Jeremy Culp
INTERIOR DESIGN: Steve Gier
COVER IMAGE: Mopic via Shutterstock.com
Interior Images: ( p.1 ) Mopic via Shutterstock.com; ( p.5 ) Patrick Nijhuis via freeimages.com; ( p.9 ) Emlyn via morguefile.com; ( p.15 ) Michael Lorenzo via freeimages.com; ( p.23 ) Public Domain.
Excerpted from The Power of Weakness: Embracing the True Source of Strength by Dan Schaeffer. Copyright © 2014 by Dan Schaeffer. Used by permission of Discovery House Publishers.
All Scripture quotations, unless otherwise indicated, are taken from the New American Standard Bible®, Copyright © 1960,1962,1963,1968,1971,1972,1973,
1975,1977,1995 by The Lockman Foundation. Used by permission.
© 2014 RBC Ministries, Grand Rapids, MI
All rights reserved.



*ទី១*

## ការទទួលស្គាល់ការពិត

លោកហាវេយ មែកខេយ(Harvey Mackay) ដែលជាអ្នកនិពន្ធ និងអ្នកជំនួញបានចែកចាយ អំពីរឿងរបស់ក្មេងប្រុសម្នាក់ អាយុ១០ឆ្នាំ ឈ្មោះម៉ាក(Mark) ដែលចង់រៀនក្បាច់គុណយូដូ ទោះគាត់បានបាត់បង់ដៃម្ខាង នៅក្នុងគ្រោះថ្នាក់ចរាចរណ៍ក៏ដោយ។ ម៉ាកក៏បានចាប់ផ្តើមរៀនក្បាច់គុណយូដូ ជាមួយគ្រូបង្វឹកជនជាតិជប៉ុនវ័យចំណាស់ម្នាក់ ហើយគាត់ហ្វឹកហាត់បានល្អ។ តែ៣ខែក្រោយមក គាត់ក៏បានបញ្ចប់ការហ្វឹកហាត់ដោយជោគជ័យ តែគេបង្រៀនគាត់តែមួយក្បាច់ប៉ុណ្ណោះ។ គាត់ក៏បានសួរគ្រូគាត់ថា ហេតុអ្វី? គ្រូគាត់ក៏បានឆ្លើយថា "មានតែក្បាច់មួយនេះទេ ដែលអ្នកអាចរៀន"។

គាត់មានការភ័ន្តភាំង តែគាត់ទុកចិត្តគ្រូរបស់គាត់ ហើយក៏បានបន្តការហ្វឹកហាត់ទៀត។ ប៉ុន្មានខែក្រោយមក គាត់ក៏បានចូលប្រកួតជាលើកដំបូង។ គាត់មានការភ្ញាក់ផ្អើល ចំពោះសមត្ថភាពខ្លួនឯង ពេលដែលគាត់បានឈ្នះការប្រកួត២វគ្គដំបូង។ ការប្រកួតវគ្គទី៣ មានការពិបាកជាងមុន តែមិនយូរប៉ុន្មាន គូប្រកួតរបស់គាត់ក៏បានបាត់បង់ការអត់ធ្មត់ ហើយក៏បានសម្រុកចូលបោកចំបាប់គាត់។ ម៉ាកក៏បានប្រើក្បាច់តែមួយ ដែលគាត់ចេះនោះ យ៉ាងស្ទាត់ជំនាញ ហើយក៏បានឈ្នះការប្រកួតទៀត។ ចូលដល់វគ្គផ្តាច់ព្រាត់ គាត់ត្រូវប្រឈមមុខដាក់គូប្រកួតដែលមានមាឌធំ និងខ្លាំងជាងគាត់ ហើយក៏មានបទពិសោធន៍ច្រើនជាងគាត់ឆ្ងាយណាស់។

ម៉ាកមានអារម្មណ៍ភិតភ័យ ហើយគេមើលដឹងថា គាត់ពិតជាភ័យមែន។

អាជ្ញាកណ្ដាលមានការបារម្ភអំពីសុខមាលភាពរបស់ម៉ាក ហើយក៏បានប្រកាសបញ្ចប់ការប្រកួតតែម្ដង។ អាជ្ញាកណ្ដាលហៀបនឹងបញ្ឈប់ការប្រកួតរវាងគូប្រកួតដែលហាក់ដូចជាមិនសមគ្នាទាល់តែសោះ តែគ្រូរបស់ម៉ាកក៏បានចូលមកឃាត់ថា "សូមឲ្យគាត់ប្រកួតចុះ"។

ការប្រកួតក៏បានបន្ត ហើយគូប្រកួតរបស់ម៉ាកក៏បានធ្វើនូវកំហុសដ៏ធំមួយ។ ភ្លាមៗនោះ ម៉ាកក៏បានប្រើក្បាច់របស់គាត់ ដើម្បីផ្ដួល ហើយក្ដៀគូប្រកួតជាប់ ដោយទទួលជ័យជម្នះក្នុងការប្រកួតទាំងមូល។ នៅតាមផ្លូវត្រឡប់មកផ្ទះវិញ ម៉ាកក៏បានពិភាក្សាជាមួយគ្រូគាត់ អំពីការប្រកួត និងក្បាច់ដែលបានប្រើក្នុងការប្រកួតមុននោះ ហើយទីបំផុត គាត់ក៏បានដាច់ចិត្តសួរគ្រូគាត់ នូវសំណួរដែលគាត់បានលាក់ទុកក្នុងចិត្តយូរហើយ។ គាត់សួរថា "ហេតុអ្វី ខ្ញុំអាចឈ្នះការប្រកួតទាំងមូល ដោយប្រើក្បាច់តែមួយ?"

គ្រូគាត់ក៏បានឆ្លើយថា "អ្នកឈ្នះ ដោយសារមូលហេតុពីរ។ ទីមួយ ក្បាច់តែមួយដែលអ្នកចេះនេះ ស្ថិតក្នុងចំណោមក្បាច់បោកចំបាប់ដែលពិបាកបំផុត ក្នុងក្បាច់គុណយូដូ តែអ្នកបានហ្វឹកហាត់ស្ទើរតែបានសម្រេចទៅហើយ។ ទីពីរ ដើម្បីទប់ទល់នឹងក្បាច់មួយនេះ គូប្រកួតរបស់អ្នកត្រូវតែចាប់ដៃខាងឆ្វេងរបស់អ្នកឲ្យជាប់"។ ប៉ុន្តែ ម៉ាកមានតែដៃស្ដាំម្ខាងប៉ុណ្ណោះ ដូចនេះ ចំណុចខ្សោយរបស់ម៉ាក បានក្លាយជាចំណុចខ្លាំងបំផុតរបស់គាត់។

យើងម្នាក់ៗមានចំណុចខ្សោយជាច្រើន ដែលយើងចង់ជំនួសដោយភាពខ្លាំងវិញ។ យើងមានការលំបាកជាច្រើន ក្នុងទំនាក់ទំនងរបស់យើង។ យើងចង់ឲ្យទំនាក់ទំនងប្ដីប្រពន្ធរបស់យើងមានភាពល្អប្រសើរឡើង។

យើងប្រហែលមិនបានបំពេញតួនាទីជាឪពុកម្ដាយបានល្អ ដូចដែលបានរំពឹងគិតនោះទេ។ កូនៗរបស់យើងហាក់ដូចជាបានធ្វើឲ្យយើងដឹងថា យើងខ្សោយប៉ុណ្ណា។ ភាពកម្សោយរបស់យើងកាន់តែមានសភាពធ្ងន់ធ្ងរ និងកាន់តែអាក្រក់ឡើង ហើយពេលនេះ យើងសង្កេតឃើញភាពកម្សោយទាំងនោះ ក្នុងកូនរបស់យើងផងដែរ។ យើងមានអារម្មណ៍ថា បរាជ័យ និងអសមត្ថភាព។ យើងដឹងថា អ្វីៗអាចមានភាពល្អប្រសើរឡើង បើសិនជា



*យើងម្នាក់ៗមានចំណុចខ្សោយជាច្រើន ដែលយើងចង់ជំនួសដោយភាពខ្លាំងវិញ។*

យើងអាចមានការផ្លាស់ប្តូរ តែយើងមិនអាចផ្លាស់ប្តូរសោះ។

នៅកន្លែងធ្វើការ ហើយប្រហែលជាមានការបាក់ទឹកចិត្ត ពេលដែលបានដឹងថា យើងមិនឆ្លាត ឬមានអំណោយទាន ដូចដែលយើងបានគិតស្មាននោះទេ។ អ្នកដទៃបានទៅចោលយើងអស់ ខណៈពេលដែលយើងហាក់ដូចជាមិនរីកចម្រើនសោះ។

យើងបានព្យាយាមសម្អាតគំនិតមិនបរិសុទ្ធ និងដេញតាមភាពបរិសុទ្ធអស់រយៈពេលជាច្រើនឆ្នាំ តែមិនឃើញមានការរីកចម្រើនសោះ។ យើងដឹងថា ការនិយាយដើមគេ ជាអំពើបាប តែយើងហាក់ដូចជាមិនអាចឈប់និយាយដើមគេ។

ការនិយាយបញ្ជោរ ធ្វើឲ្យយើងមានអារម្មណ៍ថា ខ្លួនឯងស្អាត ឬឆ្លាត ហើយយើងហាក់ដូចជាទទួលយក ដោយមិនបានគិតពិចារណាទេ។

កាលណាយើងមានវ័យកាន់តែចាស់ រូបកាយយើងក៏កាន់តែអន់ខ្សោយ។ យើងអាចប្រឈមមុខដាក់ជម្ងឺទឹកនោមផ្អែម ជម្ងឺបេះដូង ឈឺចង្កេះ ជម្ងឺក្រពះ ពិបាកបញ្ចេញចោល ឈឺក្បាល ឈឺសន្លាក់ដៃជើង ភ្នែកកាន់តែខ្សោយ និងជម្ងឺដទៃទៀត ដែលធ្វើឲ្យយើងអន់ខ្សោយ។



*ភាពកម្សោយធ្វើឲ្យយើងមានការភ័យខ្លាច ព្រោះយើងចង់មានមោទនភាព និងមានកម្លាំងខ្លាំង។*

សុខភាពផ្លូវចិត្តរបស់យើងក៏កាន់តែមានភាពផុយស្រួយ ដោយស្រ្តេស និងការថប់បារម្ភធ្វើទុក្ខយើងជាញឹកញាប់។ យូរៗទៅ រឿងតូចក៏អាចរំខានអារម្មណ៍យើងដែរ ហើយកម្លាំងចិត្តរបស់យើងក៏ធាប់អស់ គឺខុសពីមុន។

ភាពកម្សោយធ្វើឲ្យយើងមានការភ័យខ្លាច

ព្រោះយើងចង់មានមោទនភាព និងមានកម្លាំងខ្លាំង។ ជាធម្មតា គេយល់ថា ភាពកម្សោយ គឺជាការខ្វះអំណាច ឬកម្លាំង។

ស្តាប់មើលទៅដូចជាឡូហ្សិកណាស់។ តែគេគិតខុសហើយ។ ព្រះគម្ពីរមានការពន្យល់ខុសពីនេះ។ សម្រាប់គ្រីស្ទបរិស័ទ ភាពកម្សោយមិនមែនជាការខ្វះអំណាច ឬកម្លាំងនោះទេ។ តាមពិត យើងចាំបាច់ត្រូវដឹងថា : ភាពកម្សោយរបស់យើង គឺជាឱកាស ដើម្បីឲ្យយើងបានពិសោធន៍នឹងអំណាចចេស្តាព្រះ!



*ទីពីរ*

## ការផ្លាស់ប្តូរទស្សនះរបស់យើង

តើស្កប់ចិត្ត...នឹងអ្វី?

**សាវ័កប៉ុលបានរកឃើញដំណោះស្រាយដ៏អស្ចារ្យ** ដែលនាំមកនូវសេរីភាព និងការផ្លាស់ប្រែក្នុងជីវិត ពេលដែលគាត់បានពិសោធន៍នឹងអំណាចចេស្តារបស់ព្រះគ្រីស្ទ ក្នុងជីវិតគាត់។ គឺដូចដែលគាត់បានរៀបរាប់អំពីរឿងនេះ ក្នុងកណ្ឌគម្ពីរសំបុត្រ ដែលគាត់បានសរសេរផ្ញើទៅពួកជំនុំនៅក្រុងកូរិនថូសយ៉ាងដូចនេះថា :

តែទ្រង់មានព្រះបន្ទូលមកខ្ញុំថា គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកំឡាំងអញបានពេញខ្នាត ដោយសេចក្តីកំសោយ ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្តីកំសោយរបស់ខ្ញុំ ដោយអំណរជាខ្លាំង ដើម្បីឲ្យព្រះចេស្តានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ ហេតុនោះបានជាខ្ញុំអរសប្បាយក្នុងកាលដែលមានសេចក្តីកំសោយ ក្នុងកាលដែលគេត្មះតិះដៀល ក្នុងសេចក្តីលំបាកកាលគេធ្វើទុក្ខបៀតបៀន ហើយក្នុងសេចក្តីដែលខ្ញុំត្រូវចង្អៀតចង្អល់ដោយយល់ដល់ព្រះគ្រីស្ទ ដ្បិតកាលណាខ្ញុំខ្សោយ នោះខ្ញុំមានកំឡាំងយ៉ាងចំណានវិញ(២កូរិនថូស ១២:៩-១០)។

សូមកត់សម្គាល់ថា ពេលនោះ សាវ័កប៉ុលមិនគ្រាន់តែបាននិយាយថា គាត់ស្អប់ចិត្ត នឹងភាពកម្សោយរបស់គាត់ប៉ុណ្ណោះទេ តែគាត់បាននិយាយថា គាត់ "អរសប្បាយ" នឹងភាពកម្សោយ។ តើគាត់ (ឬនរណាម្នាក់) មានចិត្តអរសប្បាយ ចំពោះភាពកម្សោយរបស់ខ្លួន ដោយរបៀបណា? ជាងនេះទៅទៀត ហេតុអ្វីសាវ័កប៉ុលបានអះអាងថា "ដ្បិតកាលណាខ្ញុំខ្សោយ នោះខ្ញុំមានកំឡាំងយ៉ាងចំណាន់វិញ"?

ភាពកម្សោយ គឺផ្ទុយនឹងកម្លាំង។ តើការដែលគាត់និយាយដូចនេះ មានន័យថា "ពេលណាខ្ញុំក្តៅ នោះខ្ញុំក៏ត្រជាក់" ឬថា "ពេលណាខ្ញុំសប្បាយចិត្ត នោះខ្ញុំកើតទុក្ខឬ?"

បទគម្ពីរម៉ាថាយ ១៧:៥ និង លូកា ៣:២២ បានប្រើពាក្យជាភាសាក្រិកដូចគ្នា ក្នុងបរិបទដែលព្រះយេស៊ូវទទួលបុណ្យជ្រមុជទឹក និងពេលដែលទ្រង់បញ្ចេញពន្លឺនៃសិរីល្អ ឲ្យពួកសិស្សឃើញ ដែលកាលនោះ ព្រះទ្រង់មានបន្ទូលពីស្ថានសួគ៌មកថា "នេះជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់"។ សាវ័កប៉ុលបានអះអាងថា គាត់ "អរសប្បាយ" នឹងភាពកម្សោយរបស់គាត់ ដោយប្រើពាក្យដែលមានន័យដូចគ្នា នឹងពាក្យពេចន៍ដែលព្រះវរបិតាប្រើ ចំពោះព្រះយេស៊ូវថា ព្រះព្រះអង្គ ពេញចិត្តនិងព្រះយេស៊ូវណាស់។

## ចុះបើសិនជា . . .

ចុះបើសិនជាផ្លូវឆ្ពោះទៅរកអំណាចដ៏ពិត ដែលជាអំណាចនៃការមានព្រះជន្មឡើងវិញរបស់ព្រះគ្រីស្ទ ក្នុងជីវិតយើង មិនទទួលបានពីការព្យាយាមកាន់តែខ្លាំងនោះទេ តែបានមកពីការលះបង់ចិត្ត ដែលចង់មានអំណាច? ចុះបើសិនជា អំណាចចេស្តារបស់ព្រះអាចបង្ហាញចេញមកតាមរយៈជីវិតអ្នក តាមរបៀប ដែលអ្នកមិនដែលនឹកស្មានដល់ គឺមិនមែនដោយការព្យាយាមកាន់តែខ្លាំងលើសពីធម្មតា ដើម្បីជម្នះសេចក្តីកម្សោយរបស់អ្នកនោះទេ តែដោយការទទួលស្គាល់សេចក្តីកម្សោយរបស់យើង

ហើយឈប់រារាំងព្រះ តែអនុញ្ញាតឲ្យព្រះអង្គបង្ហាញអំណាចចេស្ដា តាមរយៈភាពកម្សោយទាំងអស់នោះវិញ? *ចុះបើសិនជាសេចក្ដីកម្សោយរបស់អ្នក គឺជាឧបករណ៍ដែលព្រះទ្រង់ប្រើ ដើម្បីបង្ហាញចេញនូវអំណាចចេស្ដាព្រះអង្គ?*



*ចុះបើសិនជាផ្លូវឆ្ពោះទៅរកអំណាចដ៏ពិត ដែលជាអំណាចនៃការមានព្រះជន្មឡើងវិញរបស់ព្រះគ្រីស្ទ ក្នុងជីវិតយើង មិនទទួលបានពីការព្យាយាមកាន់តែខ្លាំងនោះទេ តែបានមកពីការលះបង់ចិត្ត ដែលចង់មានអំណាច?*

នេះជាអ្វីដែលព្រះគម្ពីរប៊ីបបានបង្រៀនយើង ម្ដងហើយម្ដងទៀត។ នេះក៏ជាមូលហេតុដែលព្រះទ្រង់មិនបានដកចេញភាពកម្សោយរបស់សាវ័កប៉ុល ហើយហេតុអ្វីទ្រង់មិនដកភាពកម្សោយរបស់យើងចេញ នៅពេលខ្លះ។ ស្ដាប់មើលទៅដូចជាចម្លែក ប៉ុន្ដែ ការអរសប្បាយនឹងភាពកម្សោយ គឺជារបៀបនៃការរស់នៅរបស់គ្រីស្ទបរិស័ទ។

លោកិយប្រាប់យើងថា "ចូរឱបក្រសោបមកភាពខ្លាំង ហើយជម្នះភាពកម្សោយរបស់អ្នក"។ មានតែការបង្រៀនក្នុងព្រះគម្ពីរប៊ីបប៉ុណ្ណោះ ដែលបានលើកទឹកចិត្តយើងឲ្យឱបក្រសោបយកភាពកម្សោយរបស់យើង ហើយពិសោធន៍នឹងអំណាច តាមរយៈភាពកម្សោយទាំងនោះ។ អំណាចនេះមិនមែនជាអំណាចរបស់យើងទេ តែជាអំណាចនៃព្រះគ្រីស្ទ ដែលមានព្រះជន្មរស់ឡើងវិញ។ សាវ័កប៉ុលចង់ឲ្យពួកជំនុំនៅក្រុងកូរិនថូសពិសោធន៍នឹងអំណាចរបស់ព្រះ ដើម្បីឲ្យពួកគេអាចមានការស្កប់ចិត្តដ៏ពិតប្រាកដ។

## វីរៈបុរសដ៏ទន់ខ្សោយ នៃសេចក្ដីជំនឿ:
## មិនមែនមានតែយើងទេដែលមានភាពកម្សោយ!

សូមយើងស្វែងយល់ អំពីពាក្យពេចន៍ដែលសាវ័កប៉ុលបាននិយាយទៅកាន់ពួកជំនុំ នៅទីក្រុងកូរិនថូស ដូចតទៅ :

ឱបងប្អូនអើយ អ្នករាល់គ្នាឃើញថា ក្នុងពួកអ្នកដែលទ្រង់បានហៅ មិនសូវមានអ្នកប្រាជ្ញច្រើនខាងឯសាច់ឈាម ឬច្រើននាក់មានអំណាច និងច្រើននាក់ដែលមានត្រកូលខ្ពស់នោះទេ ព្រះទ្រង់បានរើសពួកល្ងង់ល្ងើនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្តីខ្មាសវិញ ទ្រង់បានរើសពួកកំសោយនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែមានសេចក្តីខ្មាស ហើយទ្រង់បានរើសអ្នកទាបថោកនៅលោកីយ៍នេះ និងពួកអ្នកដែលគេមើលងាយ ព្រមទាំងរបស់ដែលគ្មានផង ដើម្បីនឹងលើកចោលរបស់ដែលមានចេញ ប្រយោជន៍កុំឲ្យមនុស្សណាបានអួតខ្លួន នៅចំពោះព្រះឡើយ(១កូរិនថូស ១:២៦-២៩)។

មនុស្សជាច្រើន ដែលជារាស្ត្ររបស់ព្រះ មិនមានប្រភពចេញពីគ្រួសាររបស់អ្នកខ្លាំងពូកែ ឬមានអំណាចទេ។ នេះជារឿងដ៏រំភើបរីករាយ។ បានសេចក្តីថា យើងត្រូវការអំណាចចេស្តារបស់ព្រះគ្រីស្ទ ក្នុងជីវិតយើង ដើម្បីឲ្យយើងក្លាយជាស្មរបន្ទាល់ដ៏មានប្រសិទ្ធភាព និងមានអំណាច ថ្វាយព្រះអង្គ ក្នុងលោកិយនេះ។ បានសេចក្តីថា យើងជាផ្នែកមួយនៃមនុស្សទន់ខ្សោយ ដែលព្រះអង្គបានជ្រើសរើស។ហើយក៏មានន័យថា *អំណាចចេស្តារបស់ព្រះ គឺបានបង្ហាញចេញមក តាមរយៈភាពកម្សោយ គឺមិនមែនតាមរយៈភាពខ្លាំងរបស់យើងនោះទេ។*

*សិស្សដំបូងរបស់ព្រះយេស៊ូវ មិនមានប្រភពមកពីវណ្ណៈជាន់ខ្ពស់ ឬអ្នកដឹកនាំសាសនា ឬនយោបាយនោះទេ។ អ្នកដែលបានដើរតាមព្រះគ្រីស្ទ ឬបានទទួលសេចក្តីសង្រ្គោះនៅសម័យនោះ គឺជាមនុស្សតូចតាច ដែលមានដូចជា អ្នកនេសាទ ពួកបះបោរប្រឆាំងចក្រភពរ៉ូម៉ាំង អ្នកយកពន្ធ ស្ត្រីរកស៊ីផ្លូវភេទ មនុស្សកំផិត និងសាសន៍សាំម៉ារី ដែលពួកយូដារើសអើង ហើយលើកលែងតែមនុស្សមួយចំនួនតូចប៉ុណ្ណោះ ដែលជាអ្នកមានមុខមាត់ មានឥទ្ធិពល។*

មិនមែនមានតែសាវ័កប៉ុលទេ ដែលបានពិសោធន៍នឹងកម្លាំងរបស់ព្រះ

ក្នុងភាពកម្សោយរបស់គាត់។ ក្នុងព្រះគម្ពីរប៊ីបទាំងមូល យើងឃើញថា ព្រះទ្រង់បានប្រើភាពកម្សោយរបស់មនុស្សជាច្រើន ដើម្បីបង្ហាញអំណាចចេស្តាព្រះអង្គ ហើយសម្រេចនូវកិច្ចការដ៏គួរឲ្យកត់សំគាល់បំផុត។



*ក្នុងព្រះគម្ពីរប៊ីបទាំងមូល យើងឃើញថា ព្រះទ្រង់បានប្រើភាពកម្សោយរបស់មនុស្សជាច្រើន ដើម្បីបង្ហាញអំណាចចេស្តាព្រះអង្គ ហើយសម្រេចនូវកិច្ចការដ៏គួរឲ្យកត់សំគាល់បំផុត។*

ឧទាហរណ៍ : លោកយ៉ូសែបត្រូវបងប្អូនគាត់យកទៅលក់ ឲ្យធ្វើជាទាសករ ហើយក៏បានក្លាយជាទាសកររបស់លោកបូទីផាដែលជាមន្ត្រីជាន់ខ្ពស់នៅនគរអេស៊ីព្ទ ហើយក្រោយមកក៏ក្លាយជាអ្នកទោស ក្នុងគុករបស់ស្តេចផារ៉ោន (លោកុប្បត្តិ ៣៧:៣៩-៤១)។

មនុស្សជាទូទៅ មុខជាយល់ថា គាត់គ្មានអំណាចអ្វីទេ តែក្រោយមក ព្រះទ្រង់បានប្រើគាត់ ឲ្យជួយសង្គ្រោះជីវិតមនុស្សជាច្រើន ក្នុងគ្រោះអត់ឃ្លាន។

កាលនោះ ដាវីឌជាក្មេងគង្វាលចៀម ដែលគ្មានការហ្វឹកហាត់របស់ទាហាន ហើយមានមាឌតូច មិនពាក់អាវក្រោះរបស់ស្តេចសូលបាន។ តែព្រះទ្រង់បានប្រើគាត់ ឲ្យប្រយុទ្ធឈ្នះអ្នកប្រយុទ្ធដ៏ខ្លាំងពូកែបំផុតរបស់ពួកសត្រូវ ឈ្មោះ កូលីយ៉ាត(១សាំយ៉ូអែល ១៧) ហើយសូមចាំថា គាត់បានផ្តួលកូលីយ៉ាត ដោយប្រើតែដង្ហក់ និងគ្រាប់គ្រួសមួយគ្រាប់ប៉ុណ្ណោះ។

លោកដានីយ៉ែល និងមិត្តភក្តិរបស់គាត់ បីនាក់ គឺសាដ្រាក់ មែសាក់ និងអ័បេនេកោ គឺជាចំណាប់ខ្មាំង ក្នុងទឹកដីបរទេស ក្រោមការគ្រប់គ្រងរបស់ស្តេចដែលឆេវឆាវ និងមានអំណួត។ ពេលដែលគាត់ត្រូវគេទម្លាក់ចូលទៅក្នុងរូងតោ(ដានីយ៉ែល ៦) ហើយមិត្តភក្តិគាត់ត្រូវគេទម្លាក់ចូលទៅក្នុងគុកភ្លើង(ដានីយ៉ែល ៣) នោះគេគិតថា ពួកគេគ្មានអំណាច ឬគ្មានភាពខ្លាំងអ្វីទេ តែព្រះទ្រង់បានបង្ហាញចេញនូវអំណាចចេស្តាព្រះអង្គតាមរយៈភាពកម្សោយរបស់ពួកគេ។

សាវ័កប៉ុលចង់ពិសោធន៍នឹងអំណាចចេស្ដារបស់ព្រះគ្រីស្ទ ដើម្បីឲ្យបានឃើញ និងស្គាល់កិច្ចការដែលព្រះទ្រង់ធ្វើក្នុងជីវិតគាត់ តាមរបៀបដ៏ច្បាស់លាស់ ដោយគ្មានការយល់ច្រឡំ។ គាត់ចង់ដឹងថា ព្រះទ្រង់កំពុងធ្វើការ តាមរយៈភាពកម្សោយរបស់គាត់ ដើម្បីសម្រេចកិច្ចការដ៏អស្ចារ្យ ថ្វាយនគរព្រះអង្គ ដើម្បីឲ្យព្រះទ្រង់បានទទួលការសរសើរ និងសិរីល្អ។ គាត់ថែមទាំងស្ម័គ្រចិត្តលះបង់ការទូលសូម ឲ្យព្រះទ្រង់ដកបន្លាចេញពីសាច់គាត់ ព្រោះការអរសប្បាយនឹងភាពកម្សោយនោះ ឲ្យគាត់បានពិសោធន៍នឹងអំណាចចេស្ដាព្រះ ជា "រង្វាន់" ដ៏ប្រសើរ។

តើមាននរណាខ្លះ ដែលអាចនិយាយថា ខ្លួនពិតជាបានពិសោធន៍នឹងអំណាចចេស្ដារបស់ព្រះគ្រីស្ទ? មនុស្សជាច្រើនពិបាកនឹងយល់អត្ថន័យនៃការពិសោធន៍នឹងអំណាចចេស្ដាព្រះគ្រីស្ទ។



*ទី៣*

## ការទាត់កំប៉ុងដែលបាក់បែក

**បើខ្ញុំមានអារម្មណ៍ថា** ខ្លួនខ្ញុំមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើកិច្ចការអ្វីមួយ នោះខ្ញុំមិនមានអារម្មណ៍ថា ចង់ពឹងផ្អែកលើអំណាចចេស្ដាព្រះគ្រីស្ទ។ ពេលដែលខ្ញុំមិនមានអារម្មណ៍ថា ទន់ខ្សោយ ពេលណាខ្ញុំមិនដឹងថា ខ្លួនឯងពិតជាទន់ខ្សោយ នោះខ្ញុំមិនស្វែងរកអំណាចចេស្ដារបស់ព្រះគ្រីស្ទឡើយ។ នេះជាគុណវិបត្តិនៃការពឹងផ្អែកលើកម្លាំងខ្លួនឯង គឺវាអាចរារាំងមិនឲ្យអំណាចចេស្ដារបស់ព្រះគ្រីស្ទធ្វើការក្នុងយើង។ យើងអះអាងថា ខ្ញុំអាចធ្វើឲ្យទំនាក់ទំនងប្តីប្រពន្ធរបស់ខ្ញុំមានដំណើរការល្អ ខ្ញុំអាចចិញ្ចឹមកូនដ៏អស្ចារ្យ ឲ្យស្រឡាញ់ព្រះ ខ្ញុំធ្វើការងារបម្រើព្រះយ៉ាងមានប្រសិទ្ធភាព ខ្ញុំអាចមានជោគជ័យក្នុងជីវិត ខ្ញុំអាចជម្នះភាពកម្សោយផ្នែកសីលធម៌របស់ខ្ញុំ ខ្ញុំអាចទៅដល់គោលដៅ។ ខ្ញុំអាច ... ។ល។

ដរាបណា យើងសន្និស្ឋានថា យើងអាចសម្រេចកិច្ចការណាមួយដោយខ្លួនឯង មិនចាំបាច់ពឹងព្រះ នោះព្រះទ្រង់អាចបណ្ដោយឲ្យយើងធ្វើវា ដោយខ្លួនឯង។

*ការរៀបចំខ្លួនឲ្យមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើកិច្ចការរបស់យើង គឺសំខាន់ណាស់។ តាមពិត វាជាការទទួលខុសត្រូវ ចំពោះការអ្វីដែលព្រះទ្រង់ប្រទានឲ្យយើងធ្វើ។ ទោះជាយ៉ាងណាក៏ដោយ ពេលណាយើងពឹងផ្អែកទៅលើការរៀបចំខ្លួនឯងតែម្យ៉ាង នោះយើងមិនបានផ្តល់ឱកាសឲ្យព្រះទ្រង់បង្ហាញចេញនូវអំណាចចេស្តាព្រះអង្គ តាមរយៈការដែលយើងពឹងផ្អែកលើព្រះអង្គ ដែលជាផ្នែកមួយនៃការរៀបចំខ្លួនយើង។*

ហេតុអ្វីមនុស្សដែលមានបញ្ញា(ជាពិសេសសាវ័កប៉ុលដែលជាអ្នកចេះដឹងខ្ពស់) អួតអំពីភាពកម្សោយរបស់ពួកគេ? តាមធម្មតា យើងចូលចិត្តលាក់បាំងភាពកម្សោយរបស់យើង។ សាវ័កប៉ុលអួតអំពីភាពកម្សោយរបស់គាត់ ព្រោះគាត់ដឹងថា ភាពកម្សោយរបស់យើង គឺជាមធ្យោបាយដែលព្រះទ្រង់ប្រើជាញឹកញាប់ ដើម្បីបង្ហាញព្រះចេស្តាទ្រង់ ក្នុងជីវិតយើង។

យើងមានការពិបាក ហើយថែមទាំងឈឺចាប់ នៅក្នុងការទទួលស្គាល់ថា យើងមិនមែនជាប្តីប្រពន្ធដ៏អស្ចារ្យនោះទេ(ឬមិនមែនជាឪពុកម្តាយ ជាកូន មិត្តរួមការងារ ឬមិត្តភក្តិដ៏អស្ចារ្យនោះទេ) ឬទទួលស្គាល់ថា សមត្ថភាពរបស់យើង មិនគួរឲ្យស្ញប់ស្ញែង ដូចដែលយើងធ្លាប់គិតនោះទេ។ ភាគច្រើននៃភាពកម្សោយរបស់យើង គឺជាចំណុចដែលយើងបានព្យាយាមលាក់បាំង តែលោកិយបានដឹងរួចទៅហើយ។ សូមយើងគ្រាន់តែគិត អំពីផ្នែកណាខ្លះ ដែលយើងរំពឹងចង់ឲ្យខ្លួនយើងមានភាពរឹងមាំ។ ផ្នែកនោះហើយ ជាចំណុចខ្សោយ ឬភាពកម្សោយរបស់យើងនោះ។ ចំណុចទី១ ដែលយើងចាំបាច់ត្រូវរៀនសូត្រនោះ(ឬចងចាំ) គឺថា ភាពកម្សោយមិនមែនជាបរាជ័យរបស់យើងនោះទេ វាគ្រាន់



*ភាគច្រើននៃភាពកម្សោយរបស់យើង គឺជាចំណុចដែលយើងបានព្យាយាមលាក់បាំង តែលោកិយបានដឹងរួចទៅហើយ។*

តែជាចំណុចខ្សោយ ដែលយើងម្នាក់ៗមានដោយជៀសមិនរួច។

*យើងគិតថា **ការបិទបាំងភាពកម្សោយគឺជារឿងល្អ។** ប៉ុន្តែ តាមពិត ភាពកម្សោយលេចឡើងមក តាមរបៀបដែលយើងមិននឹកស្មានដល់ ហើយច្រើនតែងាយឲ្យអ្នកដទៃមើលដឹង ទោះយើងព្យាយាមលាក់បាំងយ៉ាងណាក៏ដោយ។*

ចូរយើងចាំថា ភាពកម្សោយ និងភាពខ្លាំង នៅទន្ទឹមគ្នា ក្នុងជីវិតសាវកប៉ុល។ ព្រះយេស៊ូវក៏បានស្ម័គ្រព្រះទ័យទទួលយកភាពកម្សោយ ក្នុងរូបភាពជាមនុស្ស នៅលើផែនដីផងដែរ។ ការសុគតនៅលើឈើឆ្កាង គឺជាគំរូដ៏ល្អបំផុតដែលបង្ហាញថា អំណាចចេស្តារបស់ព្រះបានបង្ហាញចេញមកយ៉ាងឥតខ្ចោះ តាមរយៈភាពកម្សោយ។ ក្នុងរូបភាពជាមនុស្ស ព្រះអង្គបានបន្ទាបព្រះកាយ ដោយចុះចូលស្តាប់បង្គាប់ព្រះវរបិតា ដល់អស់ព្រះជន្មនៅលើឈើឆ្កាង(ភីលីព ២:៨)។

*ព្រះយេស៊ូវបានពិសោធន៍នឹងភាពមានកំណត់ និងភាពកម្សោយ ក្នុងរូបភាពជាមនុស្ស។ ព្រះគម្ពីរដំណឹងល្អបានចែងថា ព្រះអង្គឃ្លានអាហារ ស្រេកទឹក អស់កម្លាំង និងមានស្ត្រេស ការឈឺចាប់ផ្លូវចិត្ត ផ្លូវអារម្មណ៍ និងផ្លូវកាយ និងបានស្គាល់ភាពកម្សោយបំផុតរបស់មនុស្ស គឺសេចក្តីស្លាប់។*

សូមយើងស្វែងយល់ប្រសាសន៍មួយទៀត របស់សាវ័កប៉ុល ដែលខុសពីទស្សនៈ និងវប្បធម៌របស់លោកិយ។ គាត់ថា "បើសិនជាគួរនឹងអួតខ្លួន នោះខ្ញុំនឹងអួតពីសេចក្តីកំសោយរបស់ខ្ញុំវិញ"(២កូរិនថូស ១១:៣០)។ បទគម្ពីរនេះមានការពិបាកយល់បន្តិច។ ត្រង់ចំណុចនេះ តើសាវ័កប៉ុលកំពុងតែនិយាយលើស ដើម្បីឲ្យមានការចាប់អារម្មណ៍ឬ?

គោលដៅរបស់សាវ័កប៉ុល គឺមិនមែនដើម្បីនាំឲ្យយើងមានការចាប់អារម្មណ៍ មកលើចំណុចខ្វះខាតរបស់គាត់(ឬការបន្ទាបខ្លួនរបស់គាត់) តែ

ផ្ទុយទៅវិញ គាត់ចង់និយាយសង្កត់ធ្ងន់ ទៅលើភាពកម្សោយ ដែលព្រះទ្រង់ប្រើ ដើម្បីបង្ហាញព្រះចេស្តាទ្រង់ឲ្យបានច្បាស់បំផុត។ ព្រះបានបង្រៀនសាវ័កប៉ុលថា អំណាចចេស្តារបស់ព្រះអង្គបានបង្ហាញចេញតាមរយៈភាពកម្សោយរបស់គាត់ ហើយគាត់ចង់ពិសោធន៍នឹងអំណាចចេស្តាទ្រង់។

មនុស្សភាគច្រើនព្រមទទួលស្គាល់ភាពកម្សោយមួយចំនួន ដែលមិនមានការគំរាមកំហែង មកលើអំណួត ឬតម្លៃរបស់ខ្លួន។

ឧទាហរណ៍ : ពួកគេតែងនិយាយថា

"ខ្ញុំមិនមែនជាកីឡាករ ដែលខ្លាំងពូកែដូចកាលពីមុនទៀយ"។

"ខ្ញុំធាត់ជាងមុនបន្តិច"។

"ខ្ញុំមិនពូកែចាំដូចកាលពីក្មេងទៀយ"។

ទាំងនេះសុទ្ធតែជាភាពកម្សោយ ដែលមានសុវត្ថិភាព នៅក្នុងការនិយាយប្រាប់គេ និងងាយស្រួលទទួលស្គាល់ ហើយតាមធម្មតា យើងថែមទាំងអាចនិយាយប្រាប់គេ ដោយទឹកមុខញញឹមទៀតផង។ ដរាបណាយើងមានអារម្មណ៍ថា មានភាពខ្លាំង ឬមានសមត្ថភាពគ្រប់គ្រាន់ ក្នុងផ្នែកមួយផ្សេងទៀត ជាពិសេសផ្នែកដែលយើងគិតថា សំខាន់ជាង នោះយើងក៏ងាយនឹងទទួលស្គាល់ភាពកម្សោយ ដែលយើងគិតថា មាន "សុវត្ថិភាព" នៅក្នុងការនិយាយប្រាប់គេ។ ប៉ុន្តែត្រង់ចំណុចនេះ យើងត្រូវចងចាំលក្ខណៈពីរយ៉ាង។ ទីមួយ ការនេះគ្រាន់តែជាការព្រមទទួលស្គាល់ភាពកម្សោយប៉ុណ្ណោះ។ សាវ័កប៉ុលបាននិយាយ អំពីការអួតអំពីភាពកម្សោយ ដោយយកវាមកនិយាយប្រាប់អ្នកដទៃ ដោយមានគោលបំណងដ៏ត្រឹមត្រូវ ហើយថែមទាំងដោយមោទនៈភាពដ៏ចម្លែក។ ទីពីរ ជាទូទៅ ការធ្វើ



*មនុស្សភាគច្រើនព្រមទទួលស្គាល់ភាពកម្សោយមួយចំនួន ដែលមិនមានការគំរាមកំហែង មកលើអំណួត ឬតម្លៃរបស់ខ្លួន។*

ដូចនេះ មិនសូវជួយលើកកម្ពស់ការស្គាល់ខ្លួនឯង ឬតម្លៃខ្លួនឯងប៉ុន្មានឡើយ។

ហេតុអ្វីយើងពិបាកទទួលស្គាល់ ឬអួតអំពីភាពកម្សោយរបស់យើង ដែលស៊ីជម្រៅ និងធ្ងន់ធ្ងរ? ប្រហែលមកពីយើងមានអារម្មណ៍ថា វានឹងគំរាមកំហែងមកលើតម្លៃរបស់យើងហើយ។

*សាវ័កប៉ុលបាននិយាយអំពី ព្រះគុណព្រះ ក្នុងបទគម្ពីរ រ៉ូម ១២:៣។ នេះជារឿងសំខាន់ណាស់។ ព្រោះ គឺតាមរយៈព្រះគុណ ដែលសាវ័កប៉ុលអាចទទួលយកភាពកម្សោយរបស់គាត់ ហើយលើកទឹកចិត្តយើងឲ្យទទួលយកភាពកម្សោយរបស់យើង ដោយការយល់ដឹងដ៏ត្រឹមត្រូវ។ បើយើងពឹងផ្អែកលើកម្លាំងរបស់យើង នោះយើងមិនអាចទទួលយកភាពកម្សោយរបស់យើងបានឡើយ។*

មនុស្សភាគច្រើនលើកតម្លៃខ្លួនឯង ដើម្បីការពារខ្លួន។ ប៉ុន្តែ សាវ័កប៉ុលបានរំឭកយើង ក្នុងសំបុត្រដែលគាត់បានសរសេរផ្ញើទៅពួកជំនុំនៅទីក្រុងរ៉ូមថា ប្រាជ្ញាកើតចេញពីការគិតយ៉ាងត្រឹមត្រូវ អំពីខ្លួនយើង។ "ដ្បិតខ្ញុំនិយាយនឹងមនុស្សទាំងអស់ក្នុងពួកអ្នករាល់គ្នា ដោយព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំថា ចូរគិតបែបឲ្យមានគំនិតនឹងធឹង តាមខ្នាតនៃសេចក្តីជំនឿ ដែលព្រះបានចែកមកអ្នករាល់គ្នានិមួយៗ កុំឲ្យមានគំនិតខ្ពស់លើសជាងគំនិត ដែលគួរគប្បីឲ្យគិតនោះឡើយ"(រ៉ូម ១២:៣)។ យើងលាក់បាំងភាពកម្សោយរបស់យើង ព្រោះយើងគិតថា វាមានផលប៉ះពាល់មកលើការគិតរបស់អ្នកដទៃ អំពីយើង ហើយយើងចង់ឲ្យគេគិតល្អអំពីយើង ហើយដោយសារយើងយល់ឃើញថា ព្រះទ្រង់សព្វព្រះទ័យឲ្យយើងគិតថា យើងរឹងមាំ ព្រោះយើងជាគ្រីស្ទាន!

យើងយល់ឃើញដូចនេះ ច្រើនតែមកពីយើងមានការយល់ច្រឡំចំពោះខគម្ពីរមួយដែលមានភាពពេញនិយមបំផុតគឺ : "ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ"(ភីលីព ៤:១៣)។ ក្នុងខគម្ពីរនេះយើងច្រើនតែផ្តោតទៅលើផ្នែក "ខ្ញុំអាចធ្វើគ្រប់

ទាំងអស់បាន" ហើយច្រើនតែភ្លេចផ្នែក "ដោយសារព្រះគ្រីស្ទដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ"។ ខ្ញុំជឿថា មនុស្សជាច្រើនមានផ្នត់គំនិត "ខ្ញុំអាចធ្វើបាន" ហេតុនេះហើយ បានជាយើងមានការទាក់ទាញចំពោះផ្នែកទីមួយនៃខគម្ពីរនេះ ហើយមានការភាន់ច្រឡំចំពោះផ្នែកទីពីរ។

ដោយសារយើងជាគ្រីស្ទបរិស័ទ នោះយើងពិតជាគួរតែមានភាពរឹងមាំជាងមនុស្សធម្មតា ព្រោះយើងមានព្រះគង់នៅជាមួយយើង ហើយមានព្រះគម្ពីរ និងពួកជំនុំផងដែរ។



*ព្រះទ្រង់សព្វព្រះទ័យឲ្យយើងដឹង ទទួលស្គាល់ និងទទួលយកភាពកម្សោយរបស់យើង រួចទូលសូមអំណាចចេស្ដារបស់ព្រះអង្គ ហើយមើលព្រះអង្គធ្វើការក្នុងជីវិតយើង។*

ប៉ុន្តែ សាវ័កប៉ុលនិយាយថា "ខ្ញុំមានកម្លាំង" គឺបន្ទាប់ពីគាត់បាននិយាយថា "ដ្បិតកាលណាខ្ញុំខ្សោយ"។ យើងប្រហែលមិនមានអារម្មណ៍ថាខ្សោយ ហើយក៏មិនឃើញ ខ្លួនយើងខ្សោយ។ ជាញឹកញាប់ ការគិតដូចនេះ គឺជាបញ្ហាធំបំផុតរបស់យើង។ ព្រោះ បើយើងមានអារម្មណ៍ថាយើងខ្លាំងក្នុងខ្លួនយើង នោះយើងក៏មានអារម្មណ៍ថា មិនត្រូវការជំនួយមកពីព្រះ ក្នុងជីវិតយើង។ *ពេលណាយើងអាចពន្យល់អំពីជោគជ័យរបស់យើង យ៉ាងងាយស្រួល ដោយគ្រាន់តែលើកឡើង អំពីការបណ្ដុះបណ្ដាល វិធីសាស្ត្រ អំណោយទាន ឬកាលៈទេសៈរបស់យើង តើយើងបានគិតដល់អំណាចចេស្ដាព្រះដែលបានជួយយើងដែរឬទេ?*

ព្រះទ្រង់សព្វព្រះទ័យឲ្យយើងដឹង ទទួលស្គាល់ និងទទួលយកភាពកម្សោយរបស់យើង រួចទូលសូមអំណាចចេស្ដារបស់ព្រះអង្គ ហើយមើលព្រះអង្គធ្វើការក្នុងជីវិតយើង។ នេះមិនមែនជាការងាយទេ ព្រោះយើងចាំបាច់ត្រូវលះបង់ផ្នត់គំនិតចាស់ ហើយទទួលយកផ្នត់គំនិតថ្មី។

ពេលណាការរស់នៅរបស់យើង មានបញ្ហា ឬបញ្ហាប្រឈម ឬក៏ទុក្ខ

ភ័យ តាមធម្មតា យើងមានប្រតិកម្មឆ្លើយតប តាមរបៀបណាមួយ។ យើងក៏បានបង្កើតទម្លាប់អាក្រក់ ដោយមិនដឹងខ្លួន។ សូមយើងចំណាយពេលបន្តិច ដើម្បីពិចារណាអំពីរឿងនេះ។

មុននឹងយើងអាចចាប់ផ្តើមមានការផ្លាស់ប្តូរ យើងចាំបាច់ត្រូវរៀនផ្លាស់ប្តូររបៀបដែលយើងមានប្រតិកម្មឆ្លើយតប ចំពោះបញ្ហា។

តើយើងឆ្លើយតប យ៉ាងដូចម្តេចខ្លះ? អ្នកខ្លះមានប្រតិកម្មឆ្លើយតបតាមរបៀបអវិជ្ជមាន :

**ឧទាហរណ៍ : ពួកគេថា :**

ខ្ញុំបោះបង់ការតស៊ូហើយ! ខ្ញុំមិនមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើវាទេ។

ខ្ញុំនឹងមិនអាចឆ្លងផុតឡើយ។ វានឹងបំផ្លាញខ្ញុំមិនខាន។

ខ្ញុំនឹងបរាជ័យ! ខ្ញុំមិនអាចធ្វើវាបានទេ!

ខ្ញុំមិនអាចជម្នះវាបានទេ។ ទោះប្រឹងប្រែងយ៉ាងណា ក៏នៅតែមិនអាចទៅរួចដែរ។

**អ្នកខ្លះទៀតមានការឆ្លើយតប ដោយវិជ្ជមានថា :**

ខ្ញុំអាចធ្វើវាបាន។ ខ្ញុំនឹងមិនបរាជ័យឡើយ។

ខ្ញុំនឹងរកឃើញវិធីធ្វើវា។ ខ្ញុំជឿថា ខ្ញុំអាចធ្វើបាន។

ខ្ញុំខ្លាំង។ វាគ្រាន់តែជារឿងតូចតាចទេ។

ខ្ញុំនឹងមិនបរាជ័យឡើយ! ខ្ញុំនឹងឆ្លងផុត!

យើងម្នាក់ៗមានការឆ្លើយតបជាទម្លាប់ ក្នុងស្ថានភាពភាគច្រើន។ អ្នកខ្លះមានទម្លាប់ឆ្លើយតបជាវិជ្ជមាន ដោយគិតថា យើងអាចឈ្នះ មនុស្សប្រភេទនេះ។ អ្នកខ្លះទៀតមានទម្លាប់ឆ្លើយតប ជាអវិជ្ជមានថា យើងមិនងាចឈ្នះ មនុស្សប្រភេទនេះបានឡើយ។ អ្នកខ្លះឆ្លើយតប ដោយមានទំនុកចិត្តលើសមត្ថភាពខ្លួនឯង ខ្លះទៀតឆ្លើយតប ដោយការមិនទុកចិត្ត

និងការព្រួយបារម្ភ។ អ្វីដែលចម្លែកនោះ ការឆ្លើយតបទាំងពីរ សុទ្ធតែខុសដូចគ្នា។

យើងឃើញថា ការឆ្លើយតបទាំងពីរ សុទ្ធតែផ្ដោតទៅលើខ្លួនឯង គឺមិនមែនទៅលើព្រះ និងទៅលើការអ្វីដែលព្រះអង្គសព្វព្រះទ័យនឹងធ្វើ ក្នុងស្ថានភាពយើងនោះឡើយ។ ការឆ្លើយតបទាំងពីរ សុទ្ធតែពិបាកជម្នះ។ ពេលណាអ្នករៀនគិតបែបអវិជ្ជមាន ដោយចង់បោះបង់ការតស៊ូ ចុះចាញ់ ឬគិតឃើញតែបរាជ័យ ក្នុងការអ្វីដែលអ្នកធ្វើ នោះភ្នែករបស់អ្នកមើលឃើញតែភាពកម្សោយរបស់អ្នកប៉ុណ្ណោះ គឺមិនឃើញអំណាចចេស្ដាព្រះអង្គនោះឡើយ។ ពេលណាអ្នករៀនគិតបែបវិជ្ជមាន ដោយជឿលើខ្លួនឯង និងទុកចិត្តលើសមត្ថភាពខ្លួនឯង ដើម្បីទទួលជោគជ័យ នោះភ្នែករបស់អ្នកផ្ដោតទៅលើសមត្ថភាពរបស់អ្នក ជាជាងផ្ដោតទៅលើអំណាចចេស្ដារបស់ព្រះ។ ក្នុងស្ថានភាពទាំងពីរនេះ យើងអាចដឹងថា យើងបានភ្លេចព្រះ និងអំណាចចេស្ដា ដែលព្រះអង្គតែងតែមានសម្រាប់យើងជានិច្ច។

ក្នុងពេលដែលយើងទន់ខ្សោយបំផុត ព្រះទ្រង់អាចរំដោះយើង តាមរបៀបដ៏មានចេស្ដា ហើយក្នុងពេលដែលយើងខ្លាំងបំផុត ព្រះអង្គអាចធ្វើលើសកម្លាំង និងអំណោយទានដែលយើងជាមនុស្សអាចធ្វើបាន។ ទោះជាយ៉ាងណាក៏ដោយ យើងប្រហែលជាមានអារម្មណ៍ថា យើងខ្សោយ និងគ្មានអំណាច នៅចំពោះព្រះដ៏មានចេស្ដា។ ទោះយើងមានប្រតិកម្មឆ្លើយតបពីដំបូងយ៉ាងដូចម្ដេចក៏ដោយ ចំពោះភាពកម្សោយ ឬបញ្ហាប្រឈមរបស់យើង បើសិនជាយើងមិនស្វែងរកព្រះអង្គ និងអំណាចចេស្ដាព្រះអង្គជាដំបូង និងជាអាទិភាពទេ នោះយើងចាំបាច់ត្រូវមានការផ្លាស់ប្ដូរ។



*ទី៤*

# ការទទួលស្គាល់អំណាចចេស្ដាព្រះ

លោកហារី ហ៊ូឌីនី(Harry Houdini) គឺជាអ្នកជំនាញខាងរំដោះខ្លួន ដែលមានឈ្មោះល្បី ខាងដោះខ្លួនពីខ្នោះច្រវ៉ាក់ គុក និងការឃុំឃាំងគ្រប់បែបយ៉ាង ដែលគេរៀបចំ ដើម្បីឃុំខ្លួនគាត់។ គាត់បានអួតជាច្រើនលើកច្រើនសារថា គ្មានគុកណា អាចដាក់គាត់ជាប់នោះទេ។ គាត់មិនដែលបរាជ័យ នៅក្នុងការរំដោះខ្លួនម្ដងណាឡើយ។

ប៉ុន្តែ មានរឿងមួយដំណាលថា មានពេលមួយនោះ លោកហ៊ូឌីនីបានដើរចូលទៅក្នុងបន្ទប់ឃុំខ្លួន ដូចកាលពីមុន ដោយស្លៀកពាក់ខោអាវធម្មតា។ ប៉ូលីសក៏បានបិទទ្វារបន្ទប់ឃុំឃាំង។ ពេលដែលគេចេញទៅអស់ គាត់ក៏បានដកដែកថែបស្ដើងដ៏រឹងមាំមួយដើម ចេញពីខ្សែក្រវ៉ាត់របស់គាត់។ គាត់ក៏បានចាប់ផ្ដើមដោះសោរ។ តែពេលនោះ គាត់ដោះមិនចេញសោះ។ ទោះគាត់ខំប្រឹងអស់ពីសមត្ថភាព អស់រយៈពេល២ម៉ោង រហូតទាល់តម្រិះ។ គាត់ក៏បានសុំចុះចាញ់ ដោយចិត្តនឿយណាយ។ ទ្វារបន្ទប់ឃុំឃាំងនៅតែមិនព្រមបើក។ លោកហ៊ូឌីនី ដែលល្បីខាងដោះសោរ ក៏បានបរាជ័យ។

តើមកពីហេតុអ្វី?

*តាមពិត ទ្វាំគុកបានភ្លេចកិបសោកបន្ទប់ឃុំឃាំង។*

អ្វីដែលគាត់ត្រូវធ្វើនោះ គឺគ្រាន់តែរុញទ្វារប៉ុណ្ណោះ នោះគាត់អាចចេញមកក្រៅបានហើយ។ តែក្នុងគំនិតគាត់ នៅតែគិតថា ទ្វារនោះជាប់សោរ។

តើអ្នកធ្លាប់ស្ថិតក្នុងស្ថានភាពដូចនេះទេ? សូមយើងគិតអំពីអ្នកដែលបានព្យាយាមយ៉ាងខ្លាំង ដើម្បីស្វែងរកអំណាចចេស្តាព្រះ សម្រាប់ជីវិតខ្លួនឯង ដោយស្វែងរកមធ្យោបាយមួយហើយ មួយទៀត ដើម្បីទទួលអំណាចចេស្តាព្រះ តែនៅតែមិនអាចបើកសោរ ដើម្បីទទួលអំណាចចេស្តាព្រះ។ ទីបំផុត ដោយការនឿយណាយ ពួកគេក៏បានបោះបង់ការព្យាយាម ដោយសន្និដ្ឋានថា អំណាចចេស្តាព្រះអង្គ មានតែនៅក្នុងការស្រមើស្រមៃ ឬសម្រាប់តែមនុស្សមួយចំនួនតូចដែលទ្រង់បានជ្រើសរើស ឬក៏សម្រាប់តែមនុស្សសម័យដើម ឬមួយអាចទទួលបានតាមមធ្យោបាយមួយចំនួនដែលពួកគេមិនទាន់រកឃើញ។

បើពួកសាវ័ករបស់ព្រះយេស៊ូវទទួលស្គាល់ថា ពួកគេមិនបានពិសោធន៍និងអំណាចចេស្តាព្រះ ក្នុងជីវិតពួកគេ នោះរឿងនេះមិនមែនជារឿងតូចឡើយ។ បើសិនជាដូច្នោះមែន ពិតជាគួរឲ្យសោកស្តាយណាស់។ ប៉ុន្តែយើងសង្កេតឃើញថា ព្រះគម្ពីរសញ្ញាថ្មីមានពេញទៅដោយព្រះបន្ទូលសន្យាប្រទានអំណាចចេស្តា ដោយរំឭកយើង អំពីធនធានដែលព្រះទ្រង់បានប្រទានឲ្យគ្រីស្ទបរិស័ទម្នាក់ៗ ដើម្បីឲ្យយើងមានជោគជ័យ ក្នុងជីវិត។

តាមធម្មតា មនុស្សស្វែងរកអំណាចចេស្តារបស់ព្រះ ដោយការភាន់ច្រឡំ។ ភាគច្រើនមនុស្សយល់ថា អំណាចមានការទាក់ទងនឹងកម្លាំងកាយធនធានខាងសាច់ឈាម ឬសក្តានុពលដ៏គួរឲ្យភ្ញាក់ផ្អើល ដែលបានបង្ហាញចេញមក។ ពេលយើងគិតអំពីអំណាច ភាគច្រើន យើងគិតថា មនុស្សប្រើអំណាចតាមរបៀបណាមួយ ដើម្បីសម្រេចបំណងខ្លួនឯង ដូចជា អ្នកមានកម្លាំងធ្វើបាបអ្នកទន់ខ្សោយ សាស្ត្រាចារ្យបញ្ចេញចំណេះដឹង ឬអ្នកជំនួញបង្អួតប្រាក់ចំណូលរបស់ខ្លួន ជាដើម។



*ព្រះគម្ពីរសញ្ញាថ្មីមានពេញទៅដោយព្រះបន្ទូលសន្យាប្រទានអំណាចចេស្តា ។*

ជាញឹកញាប់ មនុស្សមានការយល់ខុសអំពីអំណាចរបស់ព្រះ ព្រោះយើងច្រើនតែគិតតាមរបៀបខាងលើនេះ។ ម្យ៉ាងទៀត យើងច្រើនតែគិតថា អំណាចរបស់ព្រះ ធ្វើឲ្យយើងមានកម្លាំងកាយ មានចំណេះដឹងកាន់តែជ្រៅជ្រះ ឬមានទ្រព្យសម្បត្តិច្រើនជាងមុន។ ប៉ុន្តែទ្រង់បានបង្ហាញថា អំណាចចេស្តាទ្រង់ គឺជាសមត្ថភាពដែលទ្រង់មាន នៅក្នុងការសម្រេចបំណងព្រះទ័យទ្រង់ នៅគ្រប់ស្ថានភាព ដែលមានពិត និងសំខាន់ តាមដំណោះស្រាយណាមួយ ដែលទ្រង់បានជ្រើសរើស ដើម្បីសិរីល្អរបស់ទ្រង់។ អំណាចរបស់ទ្រង់ គឺអាស្រ័យទៅលើបំណងព្រះទ័យ និងសិរីល្អរបស់ទ្រង់។ យើងអាចដឹងថា យើងអាចរកឃើញអំណាចចេស្តាទ្រង់ នៅកន្លែងណា។

**អំណាចកែប្រែជីវិត:** កណ្ឌគម្ពីរសញ្ញាថ្មី គឺជាការប្រមូលផ្តុំនៃកណ្ឌគម្ពីរដែលសុទ្ធតែនិយាយ អំពីការផ្លាស់ប្តូរ គឺការផ្លាស់ប្តូរក្នុងជីវិតមនុស្ស និងក្នុងវប្បធម៌។ ជំនឿគ្រីស្ទបរិស័ទមិនបានចាប់ផ្តើម ដោយការត្រាស់ហៅមនុស្សមានអំណាចនោះឡើយ។ ក្នុងសម័យពួកជំនុំដំបូង គ្រីស្ទបរិស័ទ គឺជាមនុស្សមួយក្រុម ដែលគេមិនចូលចិត្ត គេបៀតបៀន ហើយនិយាយបង្ខូច។ តែ ៣០០ឆ្នាំក្រោយមក ចក្រភពរ៉ូម៉ាំងបានសម្រេចយកជំនឿគ្រីស្ទបរិស័ទ ធ្វើជាសាសនារបស់រដ្ឋ។

យើងឃើញថា ការផ្លាស់ប្តូរនេះ គឺដោយសារអំណាចចេស្តាព្រះបានធ្វើការជាទ្រង់ទ្រាយធំ ក្នុងប្រវត្តិសាស្ត្រ ដែលយើងមិនគួរមើលរំលង។ ព្រះទ្រង់បានចាក់បង្ហូរអំណាចចេស្តាមកលើចិត្តមនុស្សជាច្រើន ដែលនាំមកនូវការផ្លាស់ប្តូរដ៏អស្ចារ្យនេះ។

*លោកសូល ជាពួកផារិស៊ី ដែលក្រោយមក ក៏បានផ្លាស់ប្រែ ហើយប្ដូរឈ្មោះទៅជាសាវ័កប៉ុល។ ទីបន្ទាល់នៃជីវិតគាត់បានបង្ហាញនូវ**ការផ្លាស់ប្ដូរផ្ទាល់ខ្លួនដ៏អស្ចារ្យ** ដោយគាត់បានមានប្រសាសន៍អំពីខ្លួនគាត់ថា "ដែលពីដើមខ្ញុំជាអ្នកប្រមាថ ធ្វើទុក្ខបៀតបៀន ហើយព្រហើនឈ្លានពាន តែទ្រង់បានអាណិតមេត្តាដល់ខ្ញុំ ពីព្រោះខ្ញុំបានប្រព្រឹត្តដោយខ្លៅល្ងង់ ឥតមានសេចក្ដីជំនឿ តែព្រះគុណរបស់ព្រះអម្ចាស់នៃយើង បានចំរើនជាបរិបូរហូរហៀរឡើង ព្រមទាំងសេចក្ដីជំនឿ និងសេចក្ដីស្រឡាញ់ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវផង"(១ធីម៉ូថេ ១:១៣-១៤)។*

**ព្រះអង្គមានអំណាចការពារ និងជួយរាស្ត្រទ្រង់ ឲ្យអាចធ្វើនូវរឿងដែលគេមិនអាចធ្វើបាន។** តើចាំរឿងលោកដានីយ៉ែលទេ? រូងសឹង្ហស្ថិតក្នុងចំណោមកន្លែង ដែលសេចក្ដីកម្សោយរបស់គាត់បង្ហាញ ឲ្យគេឃើញអំណាចចេស្ដាព្រះ។ លោកដានីយ៉ែលមិនមានសមត្ថភាព ដើម្បីកាត់ស្រាយសុបិននោះទេ តែពេលដែលស្ដេចត្រូវការអ្នកកាត់ស្រាយសុបិន ព្រះទ្រង់ក៏បានបង្ហាញព្រះចេស្ដាព្រះអង្គ ដោយផ្ដល់ឲ្យលោកដានីយ៉ែលនូវសមត្ថភាព ដែលគាត់មិនមានពីកំណើត(ដានីយ៉ែល ២)។

តើលោកពេត្រុសអាចដើរនៅលើទឹក ទៅរកព្រះយេស៊ូវ ដោយរបៀបណា? យើងដឹងថា ការដែលលោកពេត្រុសដើរលើទឹក គឺជាខុសនឹងច្បាប់ធម្មជាតិ តែគាត់បានដើរលើទឹកបានមួយរយៈពេល ហើយគាត់ក៏បានលិចចូលក្នុងទឹក ពេលដែលជំនឿគាត់មានការរេរា(ម៉ាថាយ ១៤:២២-៣៣)។ សាវ័កនីមួយៗរបស់ព្រះគ្រីស្ទ សុទ្ធតែអាចធ្វើការអស្ចារ្យ ក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យ តាមរយៈអំណាចព្រះគ្រីស្ទ នៅក្នុងពួកគេ។

**ការរស់ពីស្លាប់ឡើងវិញ!** ការប្រោសនរណាម្នាក់ឲ្យរស់ឡើងវិញ បន្ទាប់ពីអ្នកនោះបានស្លាប់ និងកប់អស់ប៉ុន្មានថ្ងៃហើយ គឺជាការបង្ហាញចេញនូវអំណាចចេស្ដាដ៏អស្ចារ្យបំផុត។ នៅពេលដែលមនុស្សជាទីស្រឡាញ់របស់យើង មានជីវិតរស់ឡើងវិញ ដោយមានជីវិតថ្មី ដោយរូបកាយដ៏ឧត្ដម្ភ នោះមានន័យថា យើងបានឃើញព្រះចេស្ដាទ្រង់បានបង្ហាញចេញមក

តាមរបៀបដ៏អស្ចារ្យហួសក្តីស្រមៃ។

*ព្រះគម្ពីរបានកត់ទុក អំពីហេតុការណ៍មួយចំនួន **និយាយអំពីមនុស្សរស់ពីស្លាប់** ដែលមានដូចជា កូនទាំងពីនាក់របស់ស្ត្រីមេម៉ាយ(១ពង្សាវតាក្សត្រ ១៧:១៧-២៤ និង លូកា ៧:១១-១៧) ក្មេងស្រីម្នាក់(ម៉ាកុស ៥:២១-៤៣) លោកឡាសា(យ៉ូហាន ១១:១-៤៤) ក្មេងឈ្មោះអើទីកុស(កិច្ចការ ២០:៧-១២) មនុស្សជាច្រើន ដែលមានជីវិតឡើងវិញ ពេលដែលព្រះយេស៊ូវសុគត(ម៉ាថាយ ២៧:៥១-៥៣) និងជាពិសេស គឺព្រះយេស៊ូវមានព្រះជន្មឡើងវិញ(២៨:១-១០)។*

ព្រះទ្រង់បង្ហាញព្រះចេស្តាទ្រង់តាមរបៀបផ្សេងៗជាច្រើន។ ព្រះអង្គនៅតែធ្វើការអស្ចារ្យ ព្រះអង្គនៅតែកែប្រែជីវិត តាមរបៀបដ៏អស្ចារ្យ និងជានិរន្ត ហើយព្រះអង្គមានឥទ្ធិពលមកលើព្រឹត្តិការណ៍ផ្សេងៗ ដើម្បីធ្វើការអ្វីដែលយើងមិនអាចធ្វើ ដោយខ្លួនឯង។ ដូចនេះ តើហេតុអ្វីបានជាយើងមិនឃើញ និងពិសោធន៍នឹងអំណាចចេស្តាព្រះ ក្នុងជីវិតយើងទៀត?

មូលហេតុសំខាន់ទី១ នោះគឺដោយ*សារ ព្រះទ្រង់ប្រើអំណាចចេស្តាព្រះអង្គ ដើម្បីធ្វើកិច្ចការណាមួយជំនួសយើង ដើម្បីសម្រេចបំណងព្រះទ័យដ៏ឥតខ្ចោះរបស់ព្រះអង្គ។* យើងមិនតែងតែបើកចំហរចិត្ត ដើម្បីជ្រើសយកជម្រើសនេះឡើយ។ យើងមិនអាចបង្គាប់បញ្ជា មកលើអំណាចចេស្តាព្រះ ក្នុងជីវិតយើង ដូចការបញ្ជាទិញកាហ្វេនោះឡើយ។ អំណាចចេស្តាទ្រង់បង្ហាញចេញមក ដោយឆ្លុះបញ្ចាំងបំណងព្រះទ័យរបស់ព្រះអង្គ ដូចនេះ ការស្វែងរកអំណាចចេស្តាព្រះអង្គ ក្នុងជីវិតយើង គឺជាការស្វែងរកបំណងព្រះទ័យដ៏ឥតខ្ចោះរបស់ព្រះអង្គ។ យើងទូលសូមព្រះអង្គ ឲ្យជួយយើង តាមរបៀបដ៏មានអំណាចចេស្តា ដើម្បីសម្រេចបំណងព្រះទ័យទ្រង់ពេលណាយើងជួបឧបស័គ្គ។ មានតែតាមរយៈព្រះគ្រីស្ទប៉ុណ្ណោះ ដែលភាពកម្សោយរបស់យើងអាចក្លាយជាឧបករណ៍ សម្រាប់ឲ្យព្រះទ្រង់បង្ហាញអំណាចចេស្តាដ៏អស្ចារ្យបំផុត ក្នុងជីវិតយើង។

*ព្រះទ្រង់បានប្រាប់យើង អំពី**បំណងព្រះទ័យ**ដែលទ្រង់មានសម្រាប់យើង ក្នុងបទគម្ពីរ ១ថែស្សាឡូនិច ៤:៣ ៥:១៨ និង ១ពេត្រុស ២:១៥ ជាដើម។*

# ការស្វែងរកអំណាចចេស្តារបស់ព្រះ

បើយើងចង់ស្វែងរកបំណងព្រះទ័យព្រះ ក្នុងជីវិតយើង នោះជាដំបូង យើងចាំបាច់ត្រូវយល់ អំពីមូលហេតុ ដែលព្រះអង្គបានសន្យាថា នឹងប្រទានយើងនូវអំណាចចេស្តា និងត្រូវដឹងថា ព្រះអង្គប្រទានមក ដើម្បីអ្វី។

**គឺដើម្បីថ្វាយសិរីល្អដល់ព្រះ** : ជាការពិតណាស់ ព្រះទ្រង់សព្វព្រះទ័យនឹងឲ្យមនុស្សម្នាក់ៗ ដែលមានជីវិត និងស្នាព្រះហស្តទាំងអស់របស់ព្រះអង្គ ថ្វាយសិរីល្អដល់ព្រះអង្គ។ អ្វីៗដែលព្រះអង្គបានបង្កើត គឺសុទ្ធតែត្រូវបានបង្កើតដើម្បីសិរីល្អព្រះអង្គ។ ផ្នែកដទៃទៀត នៃបំណងព្រះទ័យព្រះនឹងបង្ហូរចេញពីបំណងដ៏អស្ចារ្យ និងបរិសុទ្ធនេះ។ "ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង"(កូល៉ុស ១:១៦)។ អ្វីៗទាំងអស់ ដែលព្រះបានបង្កើត ដោយរាប់បញ្ចូលទាំងយើងផង គឺត្រូវបានរចនាមក ដើម្បីថ្វាយសិរីល្អដល់ព្រះអង្គ។

**ការផ្លាស់ប្រែផ្ទាល់ខ្លួន និងភាពបរិសុទ្ធរបស់យើង** : មានគ្រីស្ទបរិស័ទខ្លះជឿថា ខ្លួននឹងមិនផ្លាស់ប្រែ។ រឿងនេះស្ថិតក្នុងចំណោមរឿងដែលសោកសៅបំផុត។ លក្ខណៈធម្មជាតិនៃអំពើបាបរបស់យើង មានអំណាចណាស់ ហើយដើម្បីយកជ័យជម្នះលើវា ក្នុងជីវិតយើង យើងត្រូវតែពឹងផ្អែកលើអំណាចចេស្តាព្រះ និងអំណាចនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ ប៉ុន្តែ ដោយសារព្រះទ្រង់សព្វព្រះទ័យឲ្យយើងផ្លាស់ប្រែ នោះព្រះអង្គនឹងប្រទានអំណាច បើយើងទូលសូម (រ៉ូម ៨១៨៣០ និង ១ កូរិនថូស ១៥:៣៥-៥០ និង ២កូរិនថូស ៣:៧-១៨)។

យើងមិនអាចល្អឥតខ្ចោះបានទេ ហើយព្រះអង្គក៏មិនបានត្រាស់ហៅយើង ឲ្យក្លាយជាមនុស្សល្អឥតខ្ចោះដែរ តែឲ្យយើងបរិសុទ្ធ។ តែការដែល

ព្រះអង្គសព្វព្រះទ័យឲ្យយើងបរិសុទ្ធ គឺចំណុចដ៏សំខាន់ក្នុងព្រះគម្ពីរប៊ីប។ ព្រះអង្គសព្វព្រះទ័យឲ្យយើងមានអំណាចចេស្តាព្រះអង្គ ក្នុងជីវិតយើង ដើម្បីឲ្យយើងមានជ័យជម្នះលើអំពើបាប(មើល ១កូរិនថូស ១០:១-១៣)។ តើនេះមិនស្ថិតក្នុងចំណោមលទ្ធផលដ៏អស្ចារ្យ នៃអំណាចចេស្តាព្រះ ក្នុងជីវិតយើងឬទេ? (មើល រ៉ូម ៦)។ តើយើងមិនភ្ញាក់ផ្អើលទេឬ ពេលដែលមនុស្សម្នាក់បានផ្លាស់ប្រែភ្លាមៗ ទៅជាមនុស្សបរិសុទ្ធ ពីមនុស្ស ដែលជាជនរងគ្រោះនៃអំពើបាប និងមានជីវិតដែលអំពើបាបបានបំផ្លាញ? តើអ្នកចង់ផ្លាស់ប្រែដូចពួកគេដែរឬទេ?

*ភាពបរិសុទ្ធ គឺមានន័យថា ញែកចេញ សម្រាប់គោលបំណងពិសេស ឬមានន័យថា គ្មានកំហុស ឬមិនមានស្នាមប្រឡាក់។*

**អំណាច ដើម្បីធ្វើបន្ទាល់:** ព្រះយេស៊ូវមានបន្ទូលថា យើងនឹងទទួលអំណាច។ ពេលដែលខ្ញុំអានបទគម្ពីរ កិច្ចការ ១:៨ ខ្ញុំមានអារម្មណ៍ថា ខគម្ពីរនេះហាក់ដូចជាប្រាប់ខ្ញុំថា "អ្នករាល់គ្នានឹងមានអារម្មណ៍ថា មានអំណាច ពេលដែលព្រះវិញ្ញាណបរិសុទ្ធយាងចុះមកសណ្ឋិតលើអ្នករាល់គ្នា ហើយការនេះនឹងធ្វើឲ្យអ្នកមានភាពងាយស្រួល និងមានភាពរលូន នៅក្នុងការធ្វើជាស្មរបន្ទាល់"។ ដូចនេះ ពេលដែលខ្ញុំមិនមានអារម្មណ៍ថា មានអំណាច នោះខ្ញុំក៏បានគិតថា ខ្ញុំមានហេតុផល ដែលមិនចាំបាច់ត្រូវទៅធ្វើបន្ទាល់។ ខ្ញុំក៏បានរង់ចាំពេលដែលខ្ញុំមានអារម្មណ៍ថាដឹងច្បាស់ ប៉ុន្តែ ព្រះទ្រង់មិនបានសន្យាថា ខ្ញុំនឹងមានអារម្មណ៍ថាដឹងច្បាស់នោះឡើយ។ តែជាញឹកញាប់ ក្នុងពេលដែលខ្ញុំមិនមានអារម្មណ៍ថា ដឹងច្បាស់(ហើយជាញឹកញាប់ ដោយការភ្ញាក់ផ្អើលយ៉ាងខ្លាំង) ព្រះអង្គបានប្រើខ្ញុំ ឲ្យនាំនរណាម្នាក់ ឲ្យស្គាល់ព្រះអង្គ។

អំណាចចេស្តាព្រះអង្គ គឺពិតជាកំពុងតែធ្វើការ។

**ជំនឿដែលចម្រើនឡើង:** ជំនឿដែលយើងមានចំពោះព្រះ មានភាពរឹង

មាំ ពេលដែលយើងមិនភាន់ប្រឡំ ចំពោះកិច្ចការដែលព្រះអង្គធ្វើ ក្នុងជីវិតយើង។ ជាងនេះទៅទៀត យើងចាំបាច់ត្រូវឃើញការដែលព្រះអង្គបានធ្វើយ៉ាងអស្ចារ្យ ដើម្បីឲ្យយើងទទួលស្គាល់ការដ៏អស្ចារ្យនោះ ពេលដែលព្រះអង្គកំពុងធ្វើការ។ ព្រះទ្រង់សព្វព្រះទ័យឲ្យជំនឿយើង ចម្រើនឡើងក្នុងព្រះអង្គ យ៉ាងឆាប់រហ័ស។ ព្រះអង្គបានត្រៀមខ្លួនជាស្រេច ដើម្បីបង្ហាញអំណាចចេស្តាព្រះអង្គ ដើម្បីឲ្យយើងមានជំនឿច្បាស់ មកលើចារិកលក្ខណៈ និងកម្លាំងរបស់ព្រះអង្គ(អេភេសូរ ៤:៧-១៦ និង ភីលីព ១:៣-៨ កូល៉ុស ២:៦-៧)។



*ព្រះអង្គបានត្រៀមខ្លួនជាស្រេច ដើម្បីបង្ហាញអំណាចចេស្តាព្រះអង្គ ដើម្បីឲ្យយើងមានជំនឿច្បាស់ មកលើចារិកលក្ខណៈ និងកម្លាំងរបស់ព្រះអង្គ។*

**កម្លាំងក្នុងពេលលំបាក** : មានពេលខ្លះ អ្វីៗហាក់ដូចជាប្រឆាំងនឹងយើង។ រាល់ការប្រឹងប្រែងរបស់យើង ដើម្បីដោះស្រាយបញ្ហាទាំងនោះ ក៏បានបរាជ័យ យើងមិនមានដំណោះស្រាយ ធនធានយើងក៏មិនមាន ហើយទ្វារក៏បានបិទមួយហើយមួយទៀត។ ទីបំផុតយើងក៏បានដឹងថា ធនធានរបស់យើងដែលជាមនុស្សមិនអាចជួយយើងបាន ហើយយើងត្រូវការជំនួយពីព្រះ ដើម្បីឲ្យយើងអាចបន្តទៅមុខទៀត។ យើងត្រូវការកម្លាំងមកពីព្រះ ដើម្បីទប់យើង ពេលដែលយើងស្ទើរតែមិនអាចឈរបាន( ទំនុកដំកើង ៣:៥ ៤១:៣ ៥៥:២២។

*ជីវិតរបស់ស្តេចដាវីឌ គឺមានពេញទៅដោយទីបន្ទាល់ នៃការដែល**ព្រះទ្រង់ប្រទានអំណាចចេស្តាទ្រង់ ក្នុងពេលដ៏ពិបាក** ដូចជាពេលដែលត្រូវផ្តួលកូលីយ៉ាត ដែលមានកម្លាំងខ្លាំងជាងទ្រង់ និងនៅពេលដែលទ្រង់រត់គេចពីការតាមសម្លាប់របស់ស្តេចសូល និងក្រោយមក រត់គេចពីអាប់សាឡុម ដែលជាបុត្រាទ្រង់។*

**ភាពស្មោះត្រង់ ដល់ទីបញ្ចប់** : ក្នុងជីវិតយើង មានពេលដែលយើងមិន

ដឹងច្បាស់ថា យើងអាចបន្តដំណើរជាមួយព្រះគ្រីស្ទឬអត់។ យើងមានអារម្មណ៍ថាហត់នឿយ បាក់ទឹកចិត្តខ្លាំង ឬមិនមានសង្ឃឹមថា នឹងអាចមានការផ្លាស់ប្តូរពិតប្រាកដ ដែលយើងមិនអាចព្យាយាមទៀត។ ក្នុងពេលនោះ យើងចាំបាច់ត្រូវដឹងថា ការមានចិត្តស្មោះត្រង់ដល់ទីបញ្ចប់ គឺជាបំណងព្រះទ័យព្រះ សម្រាប់យើងម្នាក់ៗ ហើយព្រះអង្គក៏បានសន្យាថា នឹងប្រទានអំណាច ឲ្យយើងបញ្ចប់ការរត់ប្រណាំង(ភីលីព ១:៦ ១ថែស្សាឡូនិច ៥:២៣ និង យ៉ាកុប ១:៤)។

## ការរំពឹងចង់បាន!

អ្នកបានពិសោធន៍នឹងអំណាចចេស្តាព្រះ តាមរបៀបជាច្រើន ក្នុងជីវិតអ្នក ទោះអ្នកជឿព្រះអង្គ ឬអត់ក៏ដោយ។ តែដោយសារព្រះអង្គផ្គត់ផ្គង់យើង ដោយមិនបានផ្ញើសាជាអក្សរ ឬសម្លេង តាមសំបុត្រ ឬទូរស័ព្ទ នោះជាញឹកញាប់ យើងមិនដឹងថា ជំនួយនោះមកពីព្រះអង្គទេ។

ទីមួយ បើអ្នកជាអ្នកដើរតាមព្រះគ្រីស្ទ នោះព្រះទ្រង់បង្ហាញអំណាចចេស្តាទ្រង់ នៅក្នុងសេចក្តីសង្គ្រោះរបស់អ្នក។ ក្នុងបទគម្ពីរ ១កូរិនថូស ១:១៨-១៩ សាវ័កប៉ុលបានសរសេរថា "ដ្បិតដំណឹងពីឈើឆ្កាង នោះជាសេចក្តីចំកួត ដល់អស់អ្នកដែលកំពុងតែវិនាស តែជាព្រះចេស្តានៃព្រះដល់យើងរាល់គ្នាដែលកំពុងតែបានសង្គ្រោះវិញ ព្រោះមានសេចក្តីចែងទុកមកថា «អញនឹងបំផ្លាញប្រាជ្ញារបស់ពួកអ្នកប្រាជ្ញ ហើយនិងលើកចំណេះរបស់ពួកអ្នក ដែលចេះ ចោលចេញ»"។ គ្មាននរណាម្នាក់បានសង្គ្រោះដោយសារការស្គាល់ព្រះនោះទេ។ យើងបានសង្គ្រោះដោយសារជំនឿ ដោយទ្រង់បញ្ឈប់ការរុករកដ៏ងងឹតងងល់របស់យើង និងថែមទាំងបញ្ឈប់សេចក្តីសម្អប់ដែលយើងមានចំពោះព្រះអង្គ ហើយនាំយើងចូលមករកព្រះអង្គ។

ព្រះទ្រង់ធ្វើការ តាមរបៀបដ៏អស្ចារ្យ ដោយឆ្លើយតបការអធិស្ឋាន ផ្គត់ផ្គង់យើង ប្រទានអ្វីដែលយើងត្រូវការបំផុត ប្រទានទិសដៅ ការប្រោសឲ្យជា និងក្តីសង្ឃឹម ពេលដែលយើងអស់សង្ឃឹម។

យើងអរសប្បាយចំពោះអ្វីដែលយើងទទួល តែយើងត្រូវតែមានការប្រុងប្រយ័ត្ន គឺមិនត្រូវភ្លេចថា យើងបានទទួលក្ដីអំណរនោះមកពីណា។ គ្រីស្ទបរិស័ទដែលមានការប្រុងប្រយ័ត្ន ក្លាយជាគ្រីស្ទបរិស័ទដែលដឹងគុណព្រះ ហើយគ្រីស្ទបរិស័ទដែលដឹងគុណព្រះ ក៏ក្លាយជាគ្រីស្ទបរិស័ទដែលកាន់តែមានការប្រុងប្រយ័ត្ន ព្រោះពួកគេបានដឹងថា ព្រះទ្រង់បានធ្វើការក្នុងជីវិតពួកគេ ដោយភាពស្និទ្ធស្នាលយ៉ាងណា។ ពេលដែលមនុស្សម្នាក់ដឹងថា ព្រះកំពុងធ្វើការ ក្នុងជីវិតពួកគេ ដោយភាពស្និទ្ធស្នាលយ៉ាងណា នោះការអរព្រះគុណព្រះអង្គ គឺជាការឆ្លើយតបដែលសមរម្យបំផុតរបស់គាត់។

ចូរទទួលស្គាល់ភាពកម្សោយរបស់អ្នក! ភាពកម្សោយរបស់អ្នក គឺជាកន្លែងដែលអំណាចចេស្ដាព្រះ នឹងបង្ហាញចេញមកយ៉ាងច្បាស់បំផុត ក្នុងជីវិតអ្នក។ ចូរចាំថា ព្រះទ្រង់បានសន្យាប្រទានអំណាចចេស្ដា ចូរទូលសូមព្រះអង្គ ឲ្យបង្ហាញអំណាចចេស្ដាទ្រង់ ក្នុងសេចក្ដីកម្សោយរបស់អ្នក ហើយបន្ទាប់មក ចូររង់ចាំ ព្រះអង្គបង្ហាញអំណាចចេស្ដាទ្រង់។ ចូរអនុវត្តដូចនេះ ឲ្យបានញឹកញាប់ ឲ្យក្លាយជាទម្លាប់។ ចូររៀនសម្រាកក្នុងអំណាចចេស្ដាព្រះអង្គ។ ហើយពេលដែលអ្នកចាប់ផ្ដើមមើលឃើញ និងពិសោធន៍នឹងអំណាចចេស្ដាព្រះអង្គហើយ នោះចូរថ្វាយសិរីល្អដល់ព្រះ។

នេះមិនមែនជាគំនិតដែលទើបរកឃើញថ្មីនោះទេ តែជាផ្លូវនៃជីវិតថ្មីសម្រាប់យើងរាល់គ្នា។

ខ្ញុំសង្ឃឹមថា អ្នកនឹងបានរស់នៅតាមបំណងព្រះទ័យព្រះ គឺជីវិតដែលពឹងផ្អែកលើព្រះអង្គ។

ការទទួលស្គាល់សេចក្ដីកម្សោយរបស់ខ្លួនឯង គឺមានន័យដូចនេះឯង។

# ក្រុមសៀវភៅការរុករកឃើញ

*ការងារបេសកកម្មរបស់យើងខ្ញុំ គឺដើម្បីឲ្យមនុស្សគ្រប់រូបមានឱកាសទទួល និងមានការយល់ដឹងអំពីប្រាជ្ញានៃព្រះគម្ពីរ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែ ។*

ក្រុមសៀវភៅការរុករកឃើញ បកស្រាយអំពីសេចក្តីពិតនៃព្រះយេស៊ូវគ្រីស្ទ ដល់លោកិយ ដោយប្រើធនធានដែលមានគុណភាព ដែលគួរឲ្យចាប់អារម្មណ៍ និងអាចរកបាន ដែលបង្ហាញថា ព្រះគម្ពីរមានសារៈសំខាន់បំផុត ចំពោះគ្រប់ផ្នែកទាំងអស់នៃជីវិត។ កូនសៀវភៅ នៅក្នុងក្រុមសៀវភៅការរុករកឃើញ គឺអាចរកបាន ដោយឥតគិតថ្លៃ ហើយអាចត្រូវបានប្រើសម្រាប់ការសិក្សាផ្ទាល់ខ្លួន ក្នុងក្រុមតូច ឬក្នុងការងារឈោងចាប់។

យើងខ្ញុំសូមអរគុណ សម្រាប់ការគាំទ្រធនធានរបស់ក្រុមសៀវភៅការរុករកឃើញ និងអង្គការនំម៉ាណាប្រចាំថ្ងៃ។ មានគ្រីស្ទបរិស័ទជាច្រើនបានរួមចំណែកក្នុងការដាក់ដង្វាយឧបត្ថម្ភ ទោះតិចតួច ឬច្រើនក្តី ដល់អង្គការនំម៉ាណាប្រចាំថ្ងៃ ដើម្បីឲ្យឈោងចាប់អ្នកដទៃ ដោយប្រាជ្ញានៃព្រះគម្ពីរដែលធ្វើឲ្យជីវិតផ្លាស់ប្រែ។ យើងខ្ញុំមិនបានទទួលប្រាក់ជំនួយពីក្រុម ឬនិកាយណាមួយឡើយ។

CLICK TO DONATE